របៀបបំពេញរបាយការណ៍ស្ថានភាពសិទ្ធិទទួលនៃរបាយការណ៍ប្រចាំឆមាស SAR 7 របស់លោកអ្នក

សម្រាប់អត្ថប្រយោជន៍ Cash Aid (កម្មវិធីជំនួយសាច់ប្រាក់) និង CalFresh (កាលពីមុនហៅថាបណ្ណជំនួយម្ហូបអាហារ)

សូមរក្សាទុកទម្រង់បែបបទនេះដើម្បីជួយដល់លោកអ្នកក្នុងការបំពេញ SAR 7 របស់លោកអ្នក (របាយការណ៍ស្ថានភាពសិទ្ធិទទួល)។ ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការបំពេញរបាយការណ៍របស់លោកអ្នក **សូមទូរស័ព្ទមកខោនធី (County)**។

- ប្រសិនបើលោកអ្នកមិនផ្ញើបាយការណ៍ពេញលេញមួយទេ អត្ថប្រយោជន៍របស់លោកអ្នកអាចនឹងត្រូវពន្យា ផ្លាស់ប្តូរ ឬបញ្ឈប់ ឬមួយក៏បង្កឱ្យមានការទូទាត់ជូនលើសចំនួនដែលលោកអ្នកនឹងត្រូវបង់សងមកវិញ។ លោកអ្នកត្រូវតែឆ្លើយនឹងសំណួរទាំងអស់ ហើយភ្ជាប់ភស្តុតាងមកជាមួយនៅពេលយើងស្នើសុំ។ សំណួរទី 4 និង 13 គឺ CalWORKs តែប៉ុណ្ណោះ គ្រួសារណាដែលទទួលបានតែ CalFresh គឺមិនតម្រូវឲ្យឆ្លើយសំណួរទាំងនេះទេ។
- **សូមភ្ជាប់សន្លឹកក្រដាសដាច់ដោយឡែកមួយប្រសិនបើចាំបាច់។**
- **ដំណើរហេតុដែលលោកអ្នករាយការណ៍អាចនឹងនាំឱ្យអត្ថប្រយោជន៍របស់លោកអ្នកកើនឡើង ថយចុះ ឬត្រូវបញ្ឈប់។**

សេចក្តីណែនាំ

កម្រិតញឹកញាប់ដែលលោកអ្នកត្រូវបំពេញ SAR 7
ម្តងក្នុងមួយឆ្នាំ (6 ខែបន្ទាប់ពីដាក់ពាក្យសុំ/ការបន្តថ្មីប្រចាំឆ្នាំរបស់លោកអ្នក)។
ខោនធីនឹងប្រាប់លោកអ្នកពីពេលដែល SAR 7 របស់លោកអ្នកត្រូវដល់កំណត់។

<u>ការរាយការណ៍សម្រាប់មនុស្សដែលកំពុងរស់នៅក្នុងផ្ទះរបស់លោកអ្នក</u>
ប្រសិនបើគ្រួសាររបស់លោកអ្នកទទួលជំនួយសាច់ប្រាក់ សូមរាយការណ៍ពីជំណើរហេតុសម្រាប់៖
- គ្រប់កូនបង្កើត ចិញ្ចឹម និងកូនចុងទាំងអស់។
- គ្រប់**ឱពុកម្តាយ**បង្កើត ចិញ្ចឹម និងឱពុកឬម្តាយចុង។
- **ញាតិសន្តានដែលបានទទួលជំនួយ**ផ្សេងទៀតក្នុងសំណុំឡឹងរបស់កូន។
- **រូបអ្នកផ្ទាល់** និង**ប្តីឬប្រពន្ធ ឬដៃគូក្នុងគ្រួសារដែលចុះឈ្មោះ**របស់លោកអ្នក។
- នរណាម្នាក់ដែល**អវត្តមានជាបណ្តោះអាសន្ន**ពីផ្ទះ។

ប្រសិនបើគ្រួសាររបស់លោកអ្នកទទួលបាន *CalFresh* (ដោយមាន ឬគ្មានជំនួយសាច់ប្រាក់) លោកអ្នកក៏ត្រូវរាយការណ៍ពីជំណើរហេតុសម្រាប់៖
- គ្រប់កូនទាំងអស់។
- គ្រប់មនុស្សពេញវ័យដែលពាក់ព័ន្ធទាំងអស់។
- គ្រប់អ្នកនៅក្នុងគ្រួសារផ្សេងទៀតដែលទិញ និងឆៀបចំម្ហូបអាហារជាមួយលោកអ្នកជាប្រចាំ។

<u>ការស្នើបញ្ឈប់អត្ថប្រយោជន៍</u>
- នៅលើ SAR 7 សូមបំពេញផ្នែនេះដើម្បីញ្ឈប់អត្ថប្រយោជន៍**<u>ត្រែ</u>**ក្នុងករណីដែលលោកអ្នកចង់បញ្ឈប់អត្ថប្រយោជន៍ណាមួយរបស់លោកអ្នកប៉ុណ្ណោះ។ សូមពិនិត្យមើលអត្ថប្រយោជន៍ដែលលោកអ្នកចង់បញ្ឈប់ ហើយចុះហត្ថលេខានិងចុះកាលបរិច្ចេទលើ SAR 7។ **ប្រសិនបើលោកអ្នកគ្រាន់តែចង់បញ្ឈប់អត្ថប្រយោជន៍ខ្លះៗរបស់លោកអ្នក ហើយរក្សាទុកអត្ថប្រយោជន៍ផ្សេងទៀត នោះលោកអ្នកត្រូវតែបំពេញ** នៃកដែលនៅសល់របស់ *SAR 7*។
- លោកអ្នកក៏អាចបញ្ឈប់អត្ថប្រយោជន៍របស់លោកអ្នកតាមរយៈការទាក់ទងមកខោនធីបានផងដែរ។
- ប្រសិនបើលោកអ្នកស្នើឱ្យបញ្ឈប់ជំនួយសាច់ប្រាក់របស់លោកអ្នក Medi-Cal (កម្មវិធីជំនួយពីរដ្ឋកាលីហ្វញ៉ាសម្រាប់ការថែទាំសុខភាព) របស់លោកអ្នកក៏អាចនឹងត្រូវបញ្ឈប់ ឬផ្លាស់ប្តូរផងដែរ។ លោកអ្នកអាចនឹងពុំមានសិទ្ធិទទួល Medi-Cal ឬលោកអ្នកអាចនឹងត្រូវបង់ចំណែកនៃការចំណាយសម្រាប់វា។

<u>របៀបបំពេញសំណួរនីមួយៗ</u>
ព័ត៌មានគ្រួសារ (សំណួរទី 1)
ឆៀបរាប់ពីបម្លាស់ប្តូរនានានៃអ្នកដែលរស់នៅជាមួយលោកអ្នក បម្លាស់ប្តូរអាសយដ្ឋានរបស់លោកអ្នក (រួមបញ្ចូលទាំងការផ្លាស់ប្តូរលេខផ្ទះ និងការផ្លាស់ប្តូរថ្លៃចំណាយក្នុងផ្ទះ គិតចាប់ពីការរាយការណ៍ចុងក្រោយរបស់លោកអ្នក)។ នេះរួមបញ្ចូល៖ កូនកើតថ្មី អ្នកដែលអវត្តមានបណ្តោះអាសន្នពីក្នុងផ្ទះ ឬនរណាដែលបានទទួលមរណភាពបានចូល ឬចាកចេញពីមន្ទីរពេទ្យ ស្ថាប័ន (រួមបញ្ចូលទាំងគុក ឬពន្ធនាគារ) ។ល។

បម្លាស់ប្តូរអាសយដ្ឋាន/ថ្លៃចំណាយទីលំនៅ (សំណួរទី 2 និងទី 3)
សូមផ្តល់ដល់យើងនូវដំណើរហេតុស្តីពីបម្លាស់ប្តូរទាំងឡាយទៅលើអាសយដ្ឋាន ឬលេខទូរស័ព្ទរបស់លោកអ្នក គិតចាប់ពីការរាយការណ៍ចុងក្រោយរបស់លោកអ្នក។ ប្រសិនបើលោកអ្នកកំពុងទទួលបាន CalFresh លោកអ្នកអាចនឹងត្រូវស្នើឱ្យផ្តល់ភស្តុតាងនៃថ្លៃចំណាយក្នុងផ្ទះថ្មី ដូចជាការជួល និងថ្លៃសេវាសាធារណៈនានាជាដើម។ ប្រសិនបើថ្លៃចំណាយរបស់លោកអ្នកកើនឡើងដោយសារតែមានការផ្លាស់ចេញចូល សូមប្រាកដថាត្រូវរាយពីចំនួនថ្មី។ នេះអាចនឹងបង្កើនអត្ថប្រយោជន៍ CalFresh របស់លោកអ្នកបាន។

ការគេចខ្លួន និងការរំលោភបំពានលើការដោះលែងមុនកំណត់/ការពូរទោសមានលក្ខខណ្ឌ CalWORKs តែប៉ុណ្ណោះ (សំណួរទី 4)
សំណួរនេះអនុវត្តចំពោះអ្នកកំពុងរស់នៅជាមួយលោកអ្នករួចហើយ ដែលមានជាប់ពាក់ព័ន្ធប្រការទាំងនេះ គិតចាប់ពីការរាយការណ៍ចុងក្រោយរបស់លោកអ្នក។ វាក៏សម្រាប់អ្នកដែលបានចូលមករស់នៅក្នុងគ្រួសារបស់លោកអ្នក ដែលកំពុងរត់គេចពីសំណាញ់ច្បាប់ ឬកំពុងរំលោភបំពានលើការដោះលែងមុនកំណត់/ការពូរទោសមានលក្ខខណ្ឌ។ យើងត្រូវការឈ្មោះរបស់បុគ្គលនោះ ទីកន្លែង និងកាលបរិច្ចេទនៃដីកាចាប់ខ្លួនត្រូវបានចេញ ឬការរំលោភបំពានបានកើតឡើង។

ប្រសិនបើលោកអ្នកបានរាយការណ៍នូវព័ត៌មាននេះជូនខោនធីពីមុនមកហើយ នោះលោកអ្នកពុំបាច់រាយការណ៍ព័ត៌មានដដែលៗនោះទេ។

ការចំណាយនានា (ព័ត៌មាន CalFresh) (សំណួរទី 5, 6 និង 7)
សំណួរទាំងនេះអាចនឹងកែប្រែអត្ថប្រយោជន៍ CalFresh របស់លោកអ្នកបាន។ ព័ត៌មាននេះអាចនឹងបន្ថយចំណូលដែលយើងរាប់បញ្ចូល ហើយបង្កើនអត្ថប្រយោជន៍របស់លោកអ្នក។ ចំពោះអ្នកមានវ័យ 60 ឆ្នាំឡើង ឬជាជនពិការ សូមរាយការណ៍ពីបម្លាស់ប្តូរទៅលើថ្លៃចំណាយវេជ្ជសាស្ត្រចេញពីហោប៉ៅរបស់លោកអ្នក។ ចំពោះគ្រួសារ CalFresh ណាមួយ សូមរាយការណ៍ពីបម្លាស់ប្តូរទៅលើថ្លៃចំណាយរបស់លោកអ្នកទៅលើកូន ឬមនុស្សពេញវ័យក្រោមបន្ទុកដែលត្រូវការមើលថែទាំសម្រាប់ការងារ ឬការបណ្តុះបណ្តាល។ ប្រសិនបើលោកអ្នកបង់ប្រាក់គាំពារកូន សូមរាយការណ៍ពីបម្លាស់ប្តូរទាំងឡាយទៅលើបរិមាណដែលបានបង់។ **សូមភ្ជាប់ភស្តុតាងដើម្បីមើលថាតើលោកអ្នកអាចទទួលបានអត្ថប្រយោជន៍បន្ថែមដែរឬទេ។**

ទ្រព្យកម្មសិទ្ធិ (សំណួរទី 8)
សូមរាយពីអ្នកដែលបានទទួល បានទិញ បានលក់ បានជួញដូរ បានចំណាយ ឬបានបោះបង់ទ្រព្យកម្មសិទ្ធិ។ ទ្រព្យកម្មសិទ្ធិរួមមាន៖ ដីធ្លី ផ្ទះសម្បែង រថយន្ត គណនីធនាគារ ការទូទាត់ប្រាក់ (ការឈ្នះឆ្នោត ឬល្បែងកាស៊ីណូ សន្តិសុខសង្គមប្រតិសកម្ម ប្រាក់ពន្ធត្រឡប់ -ល-)។ រួមបញ្ចូលទាំងអំណោយ និងកម្ចី។ សូមរ៉ាយរ៉ាប់ពីម្ចាស់ទ្រព្យ ប្រភេទទ្រព្យ ពេលវេលានៃការផ្លាស់ប្តូរ និងតម្លៃទ្រព្យ ("បរិមាណ" លើទម្រង់បែបបទ)។ សូមគូសប្រអប់តាមអ្វីដែលបានកើតឡើង។ **សូមភ្ជាប់ភស្តុតាងមកជាមួយ។**

ប្រសិនបើលោកអ្នកបានរាយការណ៍ និងបានផ្តល់ភស្តុតាងនៃទ្រព្យកម្មសិទ្ធិថ្មីរួចហើយ លោកអ្នកពុំបាច់រាយការណ៍ពីវាម្តងទៀតទេ លើកលែងតែមានការផ្លាស់ប្តូរណាមួយ។

ចំណូលការងារ (សំណួរទី 9)
សូមរាយនូវ**<u>គ្រប់</u>**ចំណូលទាំងអស់ដែលបានពីការងារ (ធ្វើការ) – ប្រាក់ចំណូល ប្រាក់ទឹកតែ ប្រាក់ឧបត្ថម្ភសម្រាប់ការបណ្តុះ បណ្តាល អត្ថប្រយោជន៍ ឬចំណូលផ្សេងទៀតដែលអ្នកណាម្នាក់រកបានក្នុងខែរបាយការណ៍។ សូមរាយពីបរិមាណមុនគិតពន្ធ ឬមុនកាត់ដក (បរិមាណដុល)។ **សូមភ្ជាប់ភស្តុតាងមកជាមួយ។**
- **ចំណូលការងារ**រួមមាន តែមិនកំណត់ត្រឹមតែមូលប្បទានបត្របៀវត្សរ៍ ចំណូលជាសាច់ប្រាក់ ប្រាក់វិស្សមកាល ប្រាក់បន្ថែម ប្រាក់បានពីការបម្រើការឱ្យខ្លួនឯង ចំណូលបានពីការបណ្តុះបណ្តាល ឬការងារបណ្តោះអាសន្ន ចំណូលបានពីការជួល IHSS (កម្មវិធីសេវាជំនួយនៅតាមផ្ទះ) ។ល។
- ប្រសិនបើ**បម្រើការឱ្យខ្លួនឯង** លោកអ្នកអាចទទួលបានការបន្ថយចុះ 40% សម្រាប់ការចំណាយពុំបាច់មានភស្តុតាង។ ប្រសិនបើការចំណាយរបស់លោកអ្នកខ្ពស់ជាងនេះ ហើយលោកអ្នកចង់អះអាងពីការចំណាយជាក់លាក់ សូមរាយគ្រប់ការចំណាយក្នុងអាជីវកម្មទាំងអស់លើសន្លឹកក្រដាសដាច់ដោយឡែកមួយ។ សូមភ្ជាប់ភស្តុតាងមកជាមួយ ប្រសិនបើធ្វើសយកការចំណាយជាក់លាក់។
- **ភស្តុតាង នៃការបាត់បង់ការងារ** រួមមាន តែមិនកំណត់ត្រឹមតែសំបុត្រពីនិយោជក សំបុត្រទទួលរង្វាន់ UIB ឬប្រសិនបើគ្មានការបញ្ជាក់ផ្សេងទៀតទេ ការថ្លែងបញ្ជាក់ជាលាយលក្ខណ៍អក្សរដែលបានចុះហត្ថលេខា។

បម្លាស់ប្តូរលើចំណូលការងារ (សំណួរទី 10)
យើងត្រូវការដឹងថាតើចំណូលនឹងបន្ថយដែល ឬនឹងមានការផ្លាស់ប្តូរ។ ប្រសិនបើចំណូលរបស់លោកអ្នកនឹងនៅដដែល យើងនឹងប្រើប្រាស់បរិមាណដែលលោកអ្នករាយការណ៍ជាចំណូលរបស់លោកអ្នកសម្រាប់ 6 ខែបន្ទាប់។ ប្រសិនបើលោកអ្នកដឹងថានឹងមានបម្រែបម្រួលទៅលើចំណូល សូមប្រាប់មកយើងពីមូលហេតុ បរិមាណ និងពេលវេលា។ ប្រសិនបើលោកអ្នកពុំច្បាស់ទេ នោះលោកអ្នកក៏អាចរាយការណ៍ពីការផ្លាស់ប្តូរនៅពេលដែលវាកើតឡើងបានដែរ។ ឧទាហរណ៍ ប្រសិនបើលោកអ្នកត្រូវបានគេផ្តល់ការងារមួយ ហើយដឹងពីប្រាក់ម៉ោង និងកាលវិភាគរបស់លោកអ្នក លោកអ្នកត្រូវតែរាយការណ៍ពីឡឹងនេះ សូម្បីបើលោកអ្នកពុំទាន់ចាប់ផ្តើមធ្វើការ ឬពុំទាន់ទទួលបានបៀវត្សរ៍ក្តី។ លើសពីនេះ ប្រសិនបើលោកអ្នកកំពុងតែធ្វើការតាមគេហៅ ឬមានកាលវិភាគដែលផ្លាស់ប្តូរច្រើន សូមសរសេរព័ត៌មាននេះនៅលើទម្រង់បែបបទ SAR 7 របស់លោកអ្នក។

ភស្តុតាងនៃចំណូលការងាររួមមាន តែមិនកំណត់ត្រឹមតែ៖ ចុងសន្លឹកមូលប្បទានប័ត្រ ច្បាប់ចម្លងមូលប្បទានប័ត្រ ឬសេចក្តីថ្លែងពីនិយោជក -ល- ឬរបាយការណ៍ពន្ធសម្រាប់ការបម្រើការដោយខ្លួនឯង។

ចំណូលផ្សេងទៀត (សំណួរទី 11)
សូមរាយ**<u>គ្រប់</u>**ចំណូលផ្សេងទៀតទាំងអស់ដែលបានពីប្រភពទាំងឡាយផ្សេងទៀត។ **សូមភ្ជាប់ភស្តុតាងមកជាមួយ។**
- **ចំណូលពិការភាព ឬចំណូលសោធនិវត្តន៍**រួមមាន SSI ប្រាក់សន្តិសុខសង្គម អត្ថប្រយោជន៍ពិការភាពនៃអតីតយុទ្ធជន ប្រាក់សំណងកម្មករ ឬប្រាក់ផ្តល់សម្រាប់ពិការភាព/សោធនិវត្តន៍ផ្សេងៗទៀត។
- **អត្ថប្រយោជន៍គ្មានការងារធ្វើ**
- **ផ្សេងទៀត៖** ការឈ្នះឆ្នោត ធានារ៉ាប់រងឬការទូទាត់តាមផ្លូវច្បាប់ អំណោយឬកម្ចី ជំនួយសម្រាប់ការជួល ទីជម្រក/សេវាសាធារណៈ/សំលៀកបំពាក់/ស្បៀងដែលតតគិតថ្លៃ (ឬប្រសិនបើនរណាម្នាក់បានបង់ថ្លៃចំណាយទាំងអស់នេះសម្រាប់លោកអ្នក) ឬអ្វីផ្សេងទៀត។
- **ភស្តុតាងនៃការលែង**ទទួលបានលុយផ្សេងៗ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែសំបុត្រពីអ្នកផ្តល់អត្ថប្រយោជន៍ ឬប្រសិនបើគ្មានការបញ្ជាក់ផ្សេងទៀតទេ ការថ្លែងបញ្ជាក់ជាលាយលក្ខណ៍អក្សរដែលបានចុះហត្ថលេខា។

សូមរាយពី (1) អ្នកមានចំណូល (2) ប្រភពចំណូលរបស់ពួកគេ និង (3) បរិមាណដែលទទួលបាន។

បម្លាស់ប្តូរលើចំណូលផ្សេងទៀត (សំណួរទី 12)
សូមប្រាប់យើងថាតើលោកអ្នកគិតថា ចំណូលនឹងបន្ថយដែល ឬលោកអ្នកដឹងថា វានឹងផ្លាស់ប្តូរ។ ប្រសិនបើលោកអ្នកដឹងថា វានឹងផ្លាស់ប្តូរ សូមប្រាប់យើងពីពេលដែលវានឹងផ្លាស់ប្តូរ និងចំនួនប៉ុន្មាន។

សូមមើលម្ខាងទៀតសម្រាប់ព័ត៌មានបន្ថែម

ភស្តុតាងនៃប្រភេទចំណូលផ្សេងៗទៀតរួមមាន តែមិនកំណត់ត្រឹមតែ៖ ចុងសន្លឹកមូលប្បទានប័ត្រ ច្បាប់ចម្លងមូលប្បទានប័ត្រ លិខិតផ្តល់រង្វាន់បានពីទីភ្នាក់ងារដែលលោកអ្នកបានប្រាក់។ល។

បម្លាស់ប្តូរទាំងឡាយផ្សេងទៀត (សំណួរទី 13)
សូមរាយពីរឿងផ្សេងៗទៀតដែលអាចផ្លាស់ប្តូរសិទ្ធិទទួលរបស់លោកអ្នក ឬចំនួនទឹកប្រាក់"នៃអត្ថប្រយោជន៍របស់លោកអ្នក។ ឧទាហរណ៍នៃបម្លាស់ប្តូរនានាដែលលោកអ្នកគួររាយការណ៍ត្រូវបានរាយជូនលើ SAR 7។

នរណាត្រូវចុះហត្ថលេខាលើរបាយការណ៍ប្រចាំឆមាស SAR 7
- ចំពោះ **Cash Aid** (**កម្មវិធីជំនួយសាច់ប្រាក់**)៖ លោកអ្នក និងប្តីឬប្រពន្ធរបស់លោកអ្នក ដែគូក្នុងគ្រួសារដែលបានចុះឈ្មោះ ឬភាគីឱពុកឬម្តាយម្ខាងទៀត (នៃកូនៗដែលបានទទួលជំនួយសាច់ប្រាក់) ប្រសិនបើពួកគេរស់នៅក្នុងផ្ទះរបស់លោកអ្នក។
- ចំពោះ **CalFresh**៖ មេគ្រួសារ តំណាងដែលទទួលសិទ្ធិអនុញ្ញាត ឬសមាជិកគ្រួសារដែលទទួលខុសត្រូវ។
- **ហើយចំពោះ**កម្មវិធីទាំងពីរ៖ អ្នកណាផ្សេងទៀតដែលជួយបំពេញរបាយការណ៍ អ្នកបកប្រែ ឬសាក្សីនៃហត្ថលេខារបស់លោកអ្នក។

អត្ថន័យនៃពាក្យពេចន៍របស់យើង

រត់គេចពីសំណាញ់ច្បាប់៖ បុគ្គលម្នាក់ត្រូវបានចាត់ទុកថាគេចវេស ឬរត់គេចពីសំណាញ់ច្បាប់ ប្រសិនបើដីកាចាប់ខ្លួនត្រូវបានចេញ ហើយបុគ្គលនោះបានដឹង ឬគួរបានដឹងពីដំណើរហេតុដែលក្រុមអនុវត្តច្បាប់កំពុងតាមរកគេ។

CASH AID៖ CalWORKs (កម្មវិធីឱកាសការងារនិងទំនួលខុសត្រូវចំពោះកុមារនៃរដ្ឋកាលីហ្វញ៉ា) ជំនួយសាច់ប្រាក់ដល់ជនភៀសខ្លួន (RCA) កម្មវិធីជំនួយជនរងគ្រោះដោយការជួញដូរខុសច្បាប់ និងឧក្រិដ្ឋកម្ម (TCVAP) និងជំនួយសាច់ប្រាក់ដល់អ្នកចូលរួម (ECA)។

ការបង់ប្រាក់គាំពារកូន៖ ការបង់ប្រាក់ឱ្យបុគ្គលម្នាក់ដែលលោកអ្នកត្រូវធ្វើឡើងសម្រាប់កូន ឬកូនចុងរបស់លោកអ្នក។ រាប់បញ្ចូលការបង់ប្រាក់ដែលធ្វើឡើងដោយឱពុកឬម្តាយចុង រស់នៅក្នុងផ្ទះរបស់លោកអ្នក។

SAR 7 ពេញលេញ៖ SAR 7 មួយ "ពេញលេញ" លុះត្រាតែ៖
- គ្រប់សំណួរបាទ/ចាស់រទត្រូវបានឆ្លើយ **ហើយ**
- គ្រប់ព័ត៌មានត្រូវបានបំពេញចូល **ហើយ**
- គ្រប់ភស្តុតាងមានភ្ជាប់មកជាមួយ នៅពេលដែលទម្រង់បែបបទមានស្នើសុំ **ហើយ**
- គ្រប់ហត្ថលេខាចាំបាច់ត្រូវបានចុះលើទម្រង់បែបបទ **ហើយ**
- ទម្រង់បែបបទត្រូវបានចុះហត្ថលេខា និងចុះកាលបរិច្ចេទ បន្ទាប់ពីថ្ងៃចុងក្រោយនៃខែរបាយការណ៍។

បរិមាណដុល៖ បរិមាណនៃមូលប្បទានបត្របៀវត្សរ៍ ឬមូលប្បទានបត្រផ្សេងទៀតរបស់លោកអ្នក (អត្ថប្រយោជន៍គ្មានការងារធ្វើ ការចូលសោធន៍និវត្តន៍ -ល-) មុនពេលដកពន្ធ ប្រាក់សន្តិសុខសង្គម។ល។

ការរំលោភបំពានលើការព្យូរទោសមានលក្ខខណ្ឌ ឬការដោះលែងមុនកំណត់៖ តុលាការបានរកឃើញថា លោកអ្នកបំពានទៅលើខលក្ខខណ្ឌនៃការព្យូរទោសមានលក្ខខណ្ឌ ឬការដោះលែងមុនកំណត់។ បទឧក្រិដ្ឋដើមដែលបង្ហាប់ឱ្យមានការព្យូរទោសមានលក្ខខណ្ឌ ឬការដោះលែងមុនពេលកំណត់ អាចជាបទឧក្រិដ្ឋកម្រិតធ្ងន់ ឬកម្រិតស្រាល។

ខែរបាយការណ៍៖ ខែដែលមានបង្ហាញនៅផ្នែកខាងលើនៃ SAR 7។ រាយការណ៍គ្រប់ចំណូលដែលលោកអ្នកទទួលបាន និងបម្លាស់ប្តូរទាំងឡាយដែលកើតមានក្នុងខែនេះ។

ខែប្រគល់៖ ខែដែលលោកអ្នកចុះហត្ថលេខ និងចុះកាលបរិច្ចេទលើរបាយការណ៍ ហើយធ្វើការប្រគល់វា។ ខែប្រគល់មានបង្ហាញនៅផ្នែកខាងលើនៃ SAR 7 នៅក្រោមខែរបាយការណ៍។

ផ្នែកវិញ្ញាបនកម្ម
- លោកអ្នកត្រូវចុះហត្ថលេខាលើ SAR 7 "ក្រោមទោសទណ្ឌនៃការនិយាយកុហកក្នុងសម្បថ"។ នេះមានន័យថា លោកអ្នកស្បថ (សន្យា) ថា ដំណើរហេតុដែលលោកអ្នកផ្តល់ជូនយើងគឺពិត ត្រឹមត្រូវ និងពេញលេញ។
- ការនិយាយកុហកក្នុងសម្បថគឺជាបទឧក្រិដ្ឋមួយ – វាមានន័យថា លោកអ្នកបានស្បថ (សន្យា) ថា និយាយការពិតរួចហើយលោកអ្នកពុំបានស្មោះត្រង់។

សូមចាំថា៖
- របាយការណ៍ដល់ពេលកំណត់ត្រឹមថ្ងៃទី 5 នៃខែប្រគល់។ សូមព្យាយាមប្រគល់វាឱ្យបានទាន់ពេលវេលា ដើម្បីចៀសវាងបញ្ហានានា ទាក់ទិននឹងអត្ថប្រយោជន៍របស់លោកអ្នក។
- ប្រសិនបើរបាយការណ៍របស់លោកអ្នកយឺតយ៉ាវ (បន្ទាប់ពីថ្ងៃទី 11 នៃខែប្រគល់) ពុំពេញលេញ ឬពុំបានប្រគល់ នោះអត្ថប្រយោជន៍របស់លោកអ្នកអាចនឹងត្រូវពន្យារ ផ្លាស់ប្តូរ ឬបញ្ឈប់ដែរ។
- ប្រសិនបើខោនធី (County) ទទួលបានរបាយការណ៍របស់លោកអ្នកយឺតយូរពេកក្នុងខែប្រគល់ ដែលត្រូវកាត់បន្ថយអត្ថប្រយោជន៍របស់លោកអ្នកផ្តែកតាមអ្វីដែលលោកអ្នកបានរាយការណ៍ លោកអ្នកអាចនឹងត្រូវទទួលបន្ទុកនៃការទូទាត់ជូនលើស ហើយត្រូវបង់សងវិញ។
- ប្រសិនបើរបាយការណ៍របស់លោកអ្នកពុំពេញលេញ នៅពេលលោកអ្នកប្រគល់វា នោះលោកអ្នកនឹងត្រូវបានស្នើឱ្យបញ្ចប់សំណួរទាំងឡាយដែលលោកអ្នកពុំបានឆ្លើយ និង/ឬប្រគល់ភស្តុតាងដែលរបាយការណ៍ស្នើឱ្យមាន។ អត្ថប្រយោជន៍របស់លោកអ្នកអាចនឹងត្រូវបានពន្យារ។
- ប្រសិនបើលោកអ្នកចុះហត្ថលេខា និងចុះកាលបរិច្ចេទលើរបាយការណ៍របស់លោកអ្នក មុនថ្ងៃដំបូងនៃខែប្រគល់ លោកអ្នកនឹងត្រូវស្នើឱ្យចុះហត្ថលេខា និងចុះកាលបរិច្ចេទលើវាម្តងទៀត។
- ប្រសិនបើលោកអ្នកពុំច្បាស់ពីរបៀបរាយការណ៍ អ្វីត្រូវរាយការណ៍ ឬភស្តុតាងណាខ្លះដែលលោកអ្នកត្រូវការបញ្ចូន **សូមសាកសួរមកកាន់ខោនធី។**
- ប្រសិនបើជំនួយសាច់ប្រាក់របស់លោកអ្នកត្រូវបញ្ឈប់ លោកអ្នកនៅតែអាចមានសិទ្ធិទទួលបានអត្ថប្រយោជន៍ CalFresh សូម្បីបើតឡូវ លោកអ្នកធ្វើការក៏ដោយ។
- ប្រសិនបើជំនួយសាច់ប្រាក់របស់លោកអ្នកត្រូវបញ្ឈប់ លោកអ្នកនៅតែអាចមានសិទ្ធិទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាបក្រោម Medi-Cal។

ការក្លែងបន្លំឧបត្ថម្ភធន៖
- ការក្លែងបន្លំឧបត្ថម្ភធនកើតឡើងនៅពេលលោកអ្នកខកខានពុំបានរាយការណ៍ព័ត៌មានឬរាយការណ៍ព័ត៌មានខុសដោយចេតនា ដើម្បីព្យាយាមទទួលបានអត្ថប្រយោជន៍បន្ថែម។
- ការក្លែងបន្លំគឺជាបទឧក្រិដ្ឋមួយ។

ទណ្ឌកម្មសម្រាប់ការក្លែងបន្លំឧបត្ថម្ភធន CASH AID៖ ប្រសិនបើលោកអ្នកត្រូវដាក់ទោសដោយការក្លែងបន្លំ ឬបើលោកអ្នកពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយសារតែប៉ុនប៉ង (ដោយចេតនា) មិនរាយការណ៍ពីព័ត៌មាននៃសិទ្ធិទទួលរបស់លោកអ្នកឱ្យបានត្រឹមត្រូវ លោកអ្នកអាចនឹងបាត់បង់ចំណែកនៃជំនួយសាច់ប្រាក់របស់លោកអ្នក។ រយៈពេលដែលលោកអ្នកនឹងខាតបង់ប្រាក់នេះគឺអាស្រ័យទៅលើបទឧក្រិដ្ឋណា និងថាតើលោកអ្នកបានប្រព្រឹត្តអំពើក្លែងបន្លំពីមុនមកដែរឬទេ។ លោកអ្នកក៏អាចត្រូវបង់ប្រាក់ពិន័យរហូតដល់ $10,000 និង/ឬត្រូវបញ្ចូនចូលគ្នក ឬពន្ធនាគារ រយៈពេលរហូតដល់ទៅ 3 ឆ្នាំទៀតផង។

ជំនួយសាច់ប្រាក់របស់លោកអ្នកអាចនឹងត្រូវបញ្ឈប់៖
- ចំពោះការមិនរាយការណ៍គ្រប់ដំណើរហេតុ ឬផ្តល់ដំណើរហេតុខុស៖ 6 ខែសម្រាប់លើកដំបូង 12 ខែសម្រាប់លើកទីពីរ ឬ**ជាដរាប**សម្រាប់លើកទីបី។
- ចំពោះការប្រគល់ពាក្យសុំលើសពីមួយដើម្បីទទួលបានជំនួយសម្រាប់សមាជិកគ្រួសារដដែលក្នុងករណីផ្សេងមួយទៀតក្នុងរយៈពេលតែមួយ៖ 2 ឆ្នាំសម្រាប់ការដាក់ទោសលើកដំបូង 4 ឆ្នាំសម្រាប់លើកទីពីរ និង**ជាដរាប**សម្រាប់លើកទី បី។
- ចំពោះការដាក់ទោសទណ្ឌក្លែងបន្លំឧបត្ថម្ភធនបទឧក្រិដ្ឋកម្រិតធ្ងន់៖ 2 ឆ្នាំសម្រាប់អត្ថប្រយោជន៍បន្ថែមក្រោម $2,000; 5 ឆ្នាំសម្រាប់បរិមាណចន្លោះ $2,000 ទៅ $4,999; និង**ជាដរាប**សម្រាប់បរិមាណចាប់ពី $5,000 ឡើងទៅ។
- **ជាដរាប**៖ ចំពោះការផ្តល់ភស្តុតាងស្នាក់នៅក្លែងក្លាយដល់ខោនធី ដើម្បីទទួលបានជំនួយក្នុងខោនធី ឬរដ្ឋលើសពីមួយ ក្នុងពេលតែមួយ; ចំពោះការប៉ុនប៉ង (ដោយចេតនា) ផ្តល់ដំណើរហេតុខុសដល់ខោនធីសម្រាប់កូនដែលគ្មានសិទ្ធិទទួល ឬកូនដែលពុំមានវត្តមាន; ចំពោះការទទួលបានអត្ថប្រយោជន៍សាច់ប្រាក់លើសពី $10,000 តាមរយៈការក្លែងបន្លំ; ចំពោះការទទួលទោសជាលើកទីបីសម្រាប់ការក្លែងបន្លំក្នុងតុលាការ ឬសវនាការរដ្ឋបាលមួយ។

ទណ្ឌកម្មសម្រាប់ការក្លែងបន្លំ CalFresh៖
ប្រសិនបើលោកអ្នកត្រូវបានផ្តន្ទាទោសពីបទក្លែងបន្លំ ឬប្រសិនបើលោកអ្នកគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយសារប៉ុនប៉ង (ដោយចេតនា) មិនរាយការណ៍ពីព័ត៌មានសិទ្ធិទទួលរបស់លោកអ្នកឱ្យបានត្រឹមត្រូវទេ CalFresh របស់លោកអ្នកអាចនឹងត្រូវបញ្ឈប់រយៈពេល 12 ខែសម្រាប់ការបំពានលើកដំបូង 24 ខែសម្រាប់លើកទីពីរ និង**ជាដរាប**សម្រាប់លើកទីបី។ លោកអ្នកអាចនឹងត្រូវពិន័យជាប្រាក់រហូតដល់ $250,000 និង/ឬបញ្ចូនចូលគ្នក ឬពន្ធនាគាររយៈពេល 20 ឆ្នាំ។

CalFresh របស់លោកអ្នកអាចនឹងត្រូវបានបញ្ឈប់ ប្រសិនបើលោកអ្នកជាប់ពិរុទ្ធភាពក្នុងតុលាការ ឬសវនាការរដ្ឋបាល ពីព្រោះ៖

- លោកអ្នកបានជួញដូរ ឬលក់អត្ថប្រយោជន៍ CalFresh ដើម្បីបានកាំភ្លើង អាវុធយុទ្ធភណ្ឌ ឬគ្រឿងផ្ទុះ អត្ថប្រយោជន៍ CalFresh របស់លោកអ្នកអាចនឹងត្រូវបញ្ឈប់**ជាដរាប**សម្រាប់ការបំពានលើកដំបូង។
- លោកអ្នកបានជួញដូរ ឬលក់អត្ថប្រយោជន៍ CalFresh ដើម្បីបានសារធាតុហាមឃាត់។ អត្ថប្រយោជន៍ CalFresh របស់លោកអ្នកអាចនឹងត្រូវបញ្ឈប់រយៈពេល 24 ខែសម្រាប់លើកដំបូង និង**ជាដរាប**សម្រាប់លើកទីពីរ។
- លោកអ្នកបានជួញដូរ ឬលក់អត្ថប្រយោជន៍ CalFresh ដែលមានតម្លៃចាប់ពី $500 ឡើងទៅ។ អត្ថប្រយោជន៍ CalFresh របស់លោកអ្នកអាចនឹងត្រូវបញ្ឈប់**ជាដរាប**។
- លោកអ្នកបានផ្តល់ព័ត៌មានអត្តសញ្ញាណ ឬស្នាក់នៅក្លែងក្លាយដល់ខោនធី ដើម្បីព្យាយាមទទួលបានអត្ថប្រយោជន៍ CalFresh ច្រើនជាងមួយករណីក្នុងពេលតែមួយ។ អត្ថប្រយោជន៍ CalFresh របស់លោកអ្នកអាចនឹងត្រូវបញ្ឈប់រយៈពេល 10 ឆ្នាំ។

សូមមើលម្ខាងទៀតសម្រាប់ព័ត៌មានបន្ថែម